00649077

E51/5/2

ឯកសារដើម
ORIGINAL DOCUMENT/DOCUMENT ORIGINAL
ថ្ងៃ ខែ ឆ្នាំ ទទួល (Date of receipt/Date de reception): 02 / 03 / 2011
ម៉ោង (Time/Heure): 15:00
មន្ត្រីទទួលបន្ទុកសំណុំរឿង/Case File Officer/L'agent chargé du dossier: Uch Arun

**ចំពោះមុខអង្គជំនុំជម្រះសាលាដំបូង**
**អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា**
**ពត៌មានពិស្តារនៃការដាក់ឯកសារ**

សំណុំរឿងលេខ ៖ ០០២/១៩-០៩-២០០៧/អ.វ.ត.ក/អ.ជ.ស.ដ

ដាក់ជូន : អង្គជំនុំជម្រះសាលាដំបូង
កាលបរិច្ឆេទនៃឯកសារ : ០២ មីនា ២០១១
ភាគីអ្នកដាក់ : ដើមបណ្តឹងរដ្ឋប្បវេណី
ភាសាដើម : **ភាសាខ្មែរ**

**ចំណាត់ថ្នាក់ឯកសារ**

ប្រភេទឯកសារដែលស្នើឡើង
ដោយភាគីអ្នកដាក់ឯកសារ : សាធារណៈ
ចំណាត់ថ្នាក់ឯកសារកំណត់ដោយ អ.ជ.ស.ដ : សាធារណៈ / Public
ប្រភេទនៃចំណាត់ថ្នាក់ឯកសារ :
ការពិនិត្យឯកសារបណ្តោះអាសន្នឡើងវិញ:
ឈ្មោះមន្ត្រីដែលបានពិនិត្យ:
ហត្ថលេខា:

---

**សំណើសុំបន្ថែមចំនួនទំព័រសម្រាប់ចម្លើយតបរួមទៅនឹងអញ្ញត្រកម្ម**
**របស់ជនជាប់ចោទទាំងអស់**

---

**ផ្ញើជូន:**

**អង្គជំនុំជម្រះសាលាដំបូង:**
ចៅក្រម និល ណុន ប្រធាន
ចៅក្រម ធូ មណី
ចៅក្រម យ៉ា សុខន
ចៅក្រម **Silvia CARTWRIGHT**
ចៅក្រម **Jean-Marc LAVERGNE**

**អ្នកដាក់ឯកសារ:**

**សហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណី:**
លោក ពេជ អង្គ
លោកស្រី **Elisabeth SIMONNEAU-FORT**

**សហមេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណី**

លោក ឡោ ជុនធី
លោកស្រី ជេត វណ្ណលី
លោកស្រី ស៊ីន សូវ៉ន
លោក ហុង គីមសួន
លោកស្រី ទី ស្រីនណា
Silke STUDZINSKY

លោក សំ សុគង់
លោក វ៉ែន ពៅ
លោក គីម ម៉េងឃី
លោក យុង ផានិត
លោកស្រី ម៉ុច សុវណ្ណារី
លោក គង់ ពិសី

Emmanuel ALTIT
Pascal AUBOIN
Olivier BAHOUGNE
Patrick BAUDOIN
Evelyne BOILEAU-BRANDOMIR
Philippe CANONNE
Annie DELAHAIE
Laure DESFORGES
Ferdinand DJAMMEN NZEPA
Nicole DUMAS
Isabelle DURAND
Françoise GAUTRY
Marie GUIRAUD
Emmanuel JACOMY
Martine JACQUIN
Daniel LOSQ
Christine MARTINEAU
Madhev MOHAN
Barnabé NEKUIE
Lyma Thuy NGUYEN
Elisabeth RABESANDRATANA
Julien RIVET
Fabienne TRUSSES NAPROUS
Nushin SARKARATI

**ចំលងជូន:**

**សហព្រះរាជអាជ្ញា**

លោកស្រី ជា លាង
លោក Andrew CAYLEY

**សហមេធាវីជនជាប់ចោទ អៀង សារី:**

លោក អាង ឧត្តម
លោក Michael G. KANAVAS

១. នៅថ្ងៃទី១៥ ខែកញ្ញា ឆ្នាំ២០១១ សហចៅក្រមស៊ើបអង្កេតបានចេញដីកាដំណោះស្រាយ ដោយបានសម្រេចបញ្ជូនជនជាប់ចោទ នួន ជា អៀង សារី អៀង ធីរិទ្ធ និង ខៀវ សំផន មកជំនុំជម្រះ[1] ដែលបន្ទាប់មកជនជាប់ចោទទាំង០៤រូបខាងលើបានដាក់បណ្តឹងឧទ្ធរណ៍ជំទាស់ទៅនឹងដីកាដំណោះស្រាយដោយឡែកៗពីគ្នា[2]។

២. នៅថ្ងៃទី១៣ ខែមករា ឆ្នាំ២០១១ អង្គបុរេជំនុំជម្រះបានចេញសេចក្តីសម្រេចទៅនឹងបណ្តឹងឧទ្ធរណ៍ទាំងអស់របស់ជនជាប់ចោទ[3] ហើយជាបន្តបន្ទាប់ក្រោយមក ជនជាប់ចោទទាំង៤រូបតាមរយៈសហមេធាវីរបស់ខ្លួន បានដាក់នូវករណីអញ្ញត្រកម្មមកអង្គជំនុំជម្រះសាលាដំបូង ដែលក្នុងនោះរួមមាន៖

. នួន ជា បានដាក់បណ្តឹងលើអញ្ញត្រកម្មចំនួន ២ គឺទី១ បណ្តឹងអញ្ញត្រកម្មទាក់ទងទៅនឹងយុត្តាធិការរបស់អង្គជម្រះសាលាដំបូង[4] និង អញ្ញត្រកម្មពាក់ព័ន្ធទៅនឹងនីត្យានុកូលភាពវិធានផ្ទៃក្នុង និងអនុភាពដីកាអង្គជំនុំជម្រះសាលាដំបូងចុះថ្ងៃទី១៧ មករា ២០១១[5] ដែលបន្ទាប់មក អញ្ញត្រកម្មទាំង២នេះត្រូវបានរួមបញ្ចូលគ្នាតែមួយ[6] ដែលមានចំនួន ៣១ ទំព័រជាភាសាអង់គ្លេស តាមការណែនាំរបស់អង្គជំនុំជម្រះសាលាដំបូង[7]។

. អៀង ធីរិទ្ធ បានដាក់បណ្តឹងអញ្ញត្រកម្មចំនួន១ ដែលមាន ១៩ ទំព័រជាភាសាខ្មែរ[8]។

---

[1] ដីកាដំណោះស្រាយ ចុះថ្ងៃទី ១៥ ខែកញ្ញា ឆ្នាំ២០១០ ឯកសារ D427។

[2] អៀង សារី បានដាក់បណ្តឹងឧទ្ធរណ៍ជំទាស់ទៅនឹងដីកាដំណោះស្រាយចំនួន ២ គឺឯកសារលេខ D274/5/1 និង D427/1/6 នួន ជា បានដាក់បណ្តឹងឧទ្ធរណ៍ចំនួន១ គឺឯកសារ D427/3/1 អៀង ធីរិទ្ធ បានដាក់បណ្តឹងឧទ្ធរណ៍ចំនួន១ គឺ ឯកសារ D427/2/1 ហើយ ខៀវ សំផន បានដាក់បណ្តឹងឧទ្ធរណ៍ចំនួន ១ គឺ ឯកសារ D427/4/3។

[3] សេចក្តីសម្រេច ឯកសារលេខ D427/4/14 (ករណី ខៀវ សំផន), D427/3/12 (ករណី នួន ជា និង អៀង ធីរិទ្ធ) និង D427/1/26 (ករណី អៀង សារី)។

[4] បណ្តឹងអញ្ញត្រកម្ម ចុះថ្ងៃទី៨ កុម្ភៈ ២០១១ ឯកសារលេខ E36។

[5] អញ្ញត្រកម្ម ចុះថ្ងៃទី១១ កុម្ភៈ ២០១១ ឯកសារលេខ E42។

[6] អញ្ញត្រកម្មរួមបញ្ចូលគ្នា ចុះថ្ងៃទី ២៥ កុម្ភៈ ២០១១ ឯកសារលេខ E51/3។

[7] អនុសារណៈការិយាល័យនៃមន្ត្រីជាន់ខ្ពស់ផ្នែកច្បាប់របស់ អង្គជំនុំជម្រះសាលាដំបូង ចុះថ្ងៃទី១៨ កុម្ភៈ ២០១១ ឯកសារ E51/1។

[8] អញ្ញត្រកម្មរបស់មេធាវីការពារក្តី អៀង ធីរិទ្ធ ចុះថ្ងៃទី ១៤ កុម្ភៈ ២០១១ ឯកសារ E44។

. អៀង សារី បានដាក់អញ្ញត្រកម្មចំនួន ២ គឺ ទី១ អញ្ញត្រកម្មរបស់ អៀង សារី អនុឡោមតាមវិធាន ៨៩ ដែលទាក់ទងទៅនឹងអាជ្ញាយុកាលលើអំពើបំពារបំពានធ្ងន់ធ្ងរ[9] និង ទី២ បណ្ដឹងអញ្ញត្រកម្មតាមវិធាន ៨៩ (១)(គ)[10] ដែលបន្ទាប់មក អញ្ញត្រកម្មទាំងនេះត្រូវបានបញ្ចូលគ្នាជាសង្ខេប នៅថ្ងៃទី២៥ កុម្ភៈ ២០១១[11]។

. ខៀវ សំផន បានដាក់បណ្ដឹងអញ្ញត្រកម្មចំនួន២ គឺទី១ អញ្ញត្រកម្មបឋមស្ដីពីការរលត់បណ្ដឹងអាជ្ញាចំពោះបទល្មើសជាតិ[12] និងទី២ អញ្ញត្រកម្មបឋមលើយុត្តាធិការ[13]។

៣. ដើម្បីជាប្រយោជន៍ និងការសន្សំសម្ចៃធនធានរបស់តុលាការ ក៏ដូចជាការបកប្រែឯកសារនៃអង្គភាពបកប្រែរបស់អង្គជំនុំជម្រះវិសាមញ្ញ សហមេធាវីតំណាងដើមបណ្ដឹងរដ្ឋប្បវេណីមានបំណងដាក់ចម្លើយតបរួមមួយទៅនឹងបណ្ដឹងអញ្ញត្រកម្មរបស់ជនជាប់ចោទទាំងអស់។

៤. ទោះបីយ៉ាងណាក្ដី សហមេធាវីតំណាងដើមបណ្ដឹងរដ្ឋប្បវេណីសង្កេតឃើញថា បញ្ហាអញ្ញត្រកម្មជាបញ្ហាសំខាន់មួយនៅក្នុងនីតិវិធីរបស់តុលាការ ហើយការឆ្លើយតបរួមទៅនឹងបណ្ដឹងអញ្ញត្រកម្មលើចំណុចជាច្រើនខាងលើនេះទាមទារនូវការបង្ហាញហេតុផលសមស្រប គ្រប់គ្រាន់ និងច្បាស់លាស់ និងត្រូវការប្រើប្រាស់ចំនួនទំព័រក៏សមស្របផងដែរ។ មាត្រា ៥ (១) នៃ សេចក្ដីណែនាំអនុវត្តស្ដីពីការដាក់ឯកសារនៅតុលាការ តម្រូវឲ្យភាគីដែលដាក់ឯកសារ ដាក់ឯកសារដែលមានកម្រាស់មិនលើសពី១៥ ទំព័រជាអង់គ្លេស ឬបារាំង ឬ៣០ទំព័រជាភាសាខ្មែរ។

៥. សហមេធាវីតំណាងដើមបណ្ដឹងរដ្ឋប្បវេណីយល់ឃើញថា ចំនួនកម្រាស់ទំព័រដូចបានលើកឡើងនៅក្នុងកថាខ័ណ្ឌ៤ខាងលើមិនគ្រប់គ្រាន់សម្រាប់ចម្លើយតបរួមមួយទៅនឹងរាល់បណ្ដឹងអញ្ញត្រកម្មដែលដាក់ដោយមេធាវីការពារក្ដីនោះឡើយ ក្នុងខណៈដែលចម្លើយតបនេះត្រូវមានសម្អាងហេតុគ្រប់ជ្រុងជ្រោយ និងការពារផលប្រយោជន៍ស្របច្បាប់របស់ភាគីដើមបណ្ដឹងរដ្ឋ

---

[9] អញ្ញត្រកម្ម ចុះថ្ងៃទី ១៤ កុម្ភៈ ២០១១ ឯកសារ E43។

[10] អញ្ញត្រកម្ម ចុះថ្ងៃទី ១៤ កុម្ភៈ ២០១១ ឯកសារ E48។

[11] សេចក្ដីសង្ខេបអញ្ញត្រកម្ម ចុះថ្ងៃទី ២៥ កុម្ភៈ ២០១១ ឯកសារ E51/14។

[12] អញ្ញត្រកម្មបឋម ចុះថ្ងៃទី ១៤ កុម្ភៈ ២០១១ ឯកសារ E47។

[13] អញ្ញត្រកម្មបឋម ចុះថ្ងៃទី ១៤ កុម្ភៈ ២០១១ ឯកសារ E46។

ប្បវេណី។ ក្នុងករណីនេះ សហមេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណីយល់ឃើញថា ដើម្បីឆ្លើយតបទៅនឹងបណ្តឹងអញ្ញត្រកម្មទាំងអស់របស់ជនជាប់ចោទឱ្យបានសមស្របនោះ ចម្លើយតបរួមមួយត្រូវមានកម្រាស់ចំនួន២៥ទំព័រជាភាសាបារាំង ឬអង់គ្លេស។

៦. ដោយសារហេតុផលខាងលើ សហមេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណីសូមស្នើដោយក្តីគោរពទៅអង្គជំនុំជម្រះសាលាដំបូងមេត្តាសម្រេចអនុញ្ញាតបន្ថែមចំនួនទំព័រសម្រាប់ចម្លើយតបរួមទៅនឹងអញ្ញត្រកម្មទាំងអស់របស់ជនជាប់ចោទ ទៅដល់ចំនួន ២៥ ទំព័រជាភាសាបារាំង ឬអង់គ្លេស និង ៥០ ទំព័រជាភាសាខ្មែរ។

សូមអង្គជំនុំជម្រះសាលាដំបូងមេត្តាទទួលនូវការគោរពដ៏ខ្ពង់ខ្ពស់អំពីយើងខ្ញុំ។

| កាលបរិច្ឆេទ | ឈ្មោះ | ទីកន្លែង | ហត្ថលេខា |
|---|---|---|---|
| ០២ មីនា ២០១១ | **ពេជ អង្គ**<br>សហមេធាវីនាំមុខជាតិ | ភ្នំពេញ | |
| | Elisabeth Simonneau-Fort<br>សហមេធាវីនាំមុខអន្តរជាតិ | ភ្នំពេញ | |